សហព័ន្ធស្រូវអង្ករកម្ពុជា
CAMBODIA RICE FEDERATION

# ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
# WEEKLY BULLETIN

CRF 2020/030 (ថ្ងៃទី៣១ ខែសីហា ដល់ ០៦ ខែកញ្ញា ឆ្នាំ២០២០)
CRF 2020/030 (31 August to 06 September 2020)

## សង្ខេបព័ត៌មានសំខាន់ៗអំពីវិស័យស្រូវអង្ករប្រចាំសប្តាហ៍ (Rice News Briefing)

### ក្នុងប្រទេស (In Cambodia)



### ការនាំចេញអង្ករពីខែមករា ដល់ខែសីហាមានកំណើន ៣១ ភាគរយ
### January-August milled-rice exports see 31 per cent spurt

*Phnom Penh Post: September 01, 2020*

Cambodia exported 448,203 tonnes of milled rice to international markets in the first eight months of this year, an increase of more than 31.04 per cent compared to 342,045 tonnes in the same period last year.

The General Directorate of Agriculture reported this, citing data from the General Department of Customs and Excise that was extracted from phytosanitary certificates.

Cambodia Rice Federation (CRF) secretary-general Lun Yeng said the exports were worth between $298 and $300 million. The directorate said jasmine and fragrant rice accounted for 352,802 tonnes, equivalent to 78.71 per cent of total milled-rice exports, while white long-grain rice accounted for 89,699 tonnes (20.01 per cent). (Read more)

### ៨ខែកន្លងមក កម្ពុជានាំចេញអង្ករជាង៤៥ម៉ឺនតោន ហើយបានចំណូលជិត៣០០លានដុល្លារ
### In the past 8 months, Cambodia exported more than 450,000 tons of rice and earned nearly 300 million USD

*Thmey Thmey: September 04, 2020*



ភ្នំពេញ៖ ក្នុងរយៈពេល៨ខែ ឆ្នាំ២០២០ ការនាំចេញអង្កររបស់កម្ពុជាសម្រេចបាន៤៤៨,២០៣តោន ដោយទទួលចំណូលបានជិត៣០០លានដុល្លារ។ នេះបើយោងតាមរបាយការណ៍សង្ខេបនៃការនាំចេញអង្ករកម្ពុជា របស់សហព័ន្ធស្រូវអង្ករកម្ពុជា នៅថ្ងៃទី៤ ខែកញ្ញា។

សហព័ន្ធស្រូវអង្ករកម្ពុជា បានបញ្ជាក់ថា ការសម្រេចបាននៃការនាំចេញអង្ករគ្រប់ប្រភេទជិត៤៥ម៉ឺនតោននេះ គឺបានកើនជាង៣០ភាគរយ បើប្រៀបធៀបទៅរយៈពេល៨ខែដូចគ្នា កាលឆ្នាំ២០១៩។ ក្នុងចំណោមអង្ករសរុបខាងលើនេះ កម្ពុជាបាននាំចេញទៅគោលដៅទីផ្សារប្រទេស និងតំបន់ធំៗចំនួន៤។ បើតាមសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងរយៈពេល៨ខែដើមឆ្នាំ២០២០នេះ កម្ពុជានាំអង្ករចូលទីផ្សារប្រទេសចិនបានជិត១៦ម៉ឺនតោន , សហភាពអឺរ៉ុប បានជិត១៥ម៉ឺនតោន, ប្រទេសសមាជិកអាស៊ាន បានជិត៦,១ម៉ឺនតោន.... (Read more)




### សហព័ន្ធស្រូវអង្ករកម្ពុជានិងធនាគារចិនចុះអនុស្សារណៈ
### Cambodia Rice Federation and Bank of China has signed on MOU

*Rasmei News: September 04, 2020*

សហព័ន្ធស្រូវអង្ករកម្ពុជា និងធនាគារចិន (ហុងកុង) សាខាភ្នំពេញ បានចុះអនុស្សរណៈនៃការយោគយល់គ្នាលើគម្រោងពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន លើកទី៣ ឆ្នាំ២០២០

ការចុះអនុស្សារណៈនេះបានធ្វើឡើង កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ នាទីស្នាក់ការធនាគារចិន (ហុងកុង) សាខាភ្នំពេញ ដោយ សហព័ន្ធស្រូវអង្ករកម្ពុជា (ស.អ.ក) តំណាងដោយ ឧកញ៉ា សុង សារ៉ន ប្រធានសហព័ន្ធ និង ធនាគារចិន (ហុងកុង) សាខាភ្នំពេញ ដែលតំណាងដោយលោក លីវ ចេន ( Liu Zheng) ។ ក្នុងនាមជាដៃគូយុទ្ធសាស្រ្តមួយរបស់ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិនលើកទី៣ ធនាគារចិន (ហុងកុង) យល់ឃើញនិងទទួលស្គាល់ ស.អ.ក ជាសមាគមធុរកិច្ចសំខាន់នៅកម្ពុជា ជាមួយនឹងគុណសម្បត្តិនៃការដែល សហព័ន្ធមានសមាជិកជាច្រើន ជាពិសេស គឺក្រុមហ៊ុននាំចេញ និងរោងម៉ាស៊ីនកិនស្រូវ ដែលជាឱកាស ក្នុងការ (Read more)

### សហព័ន្ធស្រូវអង្ករកម្ពុជាស្វែងរកឱកាសអាជីវកម្មបន្ថែមទៀតសម្រាប់វិស័យស្រូវអង្ករនៅកម្ពុជា
### CRF seeks more business opportunities for Cambodia's rice sector

*Khmer Times: September 05, 2020*




Cambodia Rice Federation (CRF) and Bank of China (Hong Kong) Limited have signed a Memorandum of Understanding (MoU) at the 3rd China International Import Expo (CIIE) project to promote the kingdom's rice industry.

The MoU was signed by Song Saran, president of CRF, and Bank of China (Hong Kong) Limited Phnom Penh Branch (BOC), represented by Liu Zheng. "As the strategic partner of the 3rd CIIE, BOC acknowledges CRF as the important business association in Cambodia with advantages of having many corporate members," Saran said. He said it will actively introduce corporate members to BOC, having the intention to participate in the CIIE for CRF's members getting opportunities in global trade and... (Read more)



### សហព័ន្ធស្រូវអង្ករកម្ពុជា និងធនាគារចិន ចុះអនុស្សរណៈយោគយល់ ដើម្បីផ្សព្វផ្សាយវិស័យស្រូវអង្ករ

## CRF, China-owned bank ink MoU to promote rice sector

*Phnom Penh Post: September 06, 2020*

Cambodia milled-rice export market is expected to widen next year after the Cambodia Rice Federation (CRF) and Bank of China (Hong Kong) Ltd (BoC) signed a Memorandum of Understanding (MoU) on cooperation and support tied to the upcoming 3rd China International Import Expo (CIIE) in November.

The MoU was signed on Friday between CRF president Song Saran and BoC Phnom Penh Branch representative Liu Zheng and aims to shore up the Kingdom's rice industry. BoC is a subsidiary of the Chinese State-owned Bank of China Ltd. Both parties will further strengthen cooperation between banks and enterprises, and "effectively and efficiently" provide services and financing for Cambodian companies that are interested in attending the CIIE. (Read more)



# អន្តរជាតិ ( International )

ឥណ្ឌា ( India )

### អ្នកនាំចេញអង្ករក្រៅពី Basmati មើលឃើញពីតម្រូវការខ្ពស់ ខណៈតម្លៃឡើងថ្លៃ នៅវៀតណាម និងថៃ

## Non-basmati rice exporters see huge demand as prices increase in Vietnam and Thailand

*The Economic Times: August 31, 2020*




KOLKATA: Indian exporters of non-basmati rice have seen a surge in orders after the price of the grain increased in Vietnam and Thailand. Indian rice is now cheaper than the Southeast Asian varieties by almost $100 per tonne.

"Export demand for non-basmati rice remains robust due to price rise in Vietnam and Thailand. Their rice is commanding a price of $490-500 per tonne, whereas our price is around (Read more)

ជប៉ុន ( Japan )

### តម្លៃអង្ករបស់ជប៉ុន ប្រហែលជាអាចធ្លាក់នៅក្នុងពេល៦ខែដំបូង

## Japan rice prices may fall for first time in six years

*Japan Times: September 01, 2020*

Wholesale prices of rice to be harvested this year are likely to fall for the first time in six years, helping consumers while giving farmers a headache.

The drop reflects lower demand for dining out because of the novel coronavirus epidemic, on top of a population decline and a continued shift in consumer preference away from the traditional staple food. The wholesale prices mean the prices of rice changing hands between shippers, including agricultural cooperatives, and wholesalers.

Rice demand over the year through June stood at 7.13 million tons on a preliminary basis, down 220,000 tons from the preceding year, the agriculture ministry said. (Read more)

ហ្គាណា ( Ghana )

### អនុរដ្ឋមន្ត្រីក្រសួងកសិកម្មៈ ហ្គាណានឹងឈប់នាំចូលអង្ករ នៅក្នុងរដូវដាំដុះ ឆ្នាំ២០២២-២០២៣

## Ghana to stop importing rice by 2022-2023 crop season – Deputy Agric Minister

*Ghana Web: September 02, 2020*

Deputy Minister of Agriculture, George Boahen Oduro, has promised that Government of Ghana will stop the importation of rice into the country by the end of the 2022/2023 crop season.

"Since the lockdown, we have not imported any rice, we are only consuming our local rice and the ones that were locked up in the system…the government bought the 600,000 metric tonnes of Ghana rice, we are now giving a seed of 11000 tonnes to our farmers…," he said.

Speaking on Angel 102.9FM's Morning Show, Mr Oduro was confident the country (Read more)

### សន្ទស្សន៍ថ្លៃអាហារពិភពលោកកើនឡើងជាលើកទី៣ គិតត្រឹមខែសីហាៈ អង្គការ FAO

## World food price index rises for third month running in August: FAO

*Reuters: September 03, 2020*

ROME (Reuters) - World food prices rose for a third month running in August, led by coarse grains, vegetable oils and sugar, the United Nations food agency said on Thursday.



The Food and Agriculture Organization's food price index, which measures monthly changes for a basket of cereals, oilseeds, dairy products, meat and sugar, averaged 96.1 points last month versus 94.3 in July. The Rome-based FAO (Read more)

វៀតណាម ( Vietnam )

### កសិកររំពឹងទទួលបានផលច្រើនជាងមុនពីដំណាំនៅក្នុងរដូវស្លឹកឈើជ្រុះ និងរងា

## Farmers expect more profitable fall-winter crop

*SGGP: September 04, 2020*

While farmers in the Mekong Delta are eager to harvest the bumper summer-fall crops because of high price and demand of rice, the forecast of low flood level made them more exciting to grow the fall-winter crop.



According to the Department of Agriculture and Rural Development in An Giang Province to the west, farmers have harvested approximately 227,000-ha summer-fall crop with (Read more)

Nigeria

### ទឹកជំនន់បានធ្វើឱ្យទិន្នផលស្រូវរបស់ Nigeria បាត់បង់ជាង២៥%

## Floods Washed Away More Than 25% of Nigeria's Rice Harvest

*Bloomberg: September 05, 2020*

Floods washed away at least two million tons of rice in Nigeria, the second-largest importer of the grain. That is more than 25% of the previously projected national output of 8 million tons, according to estimates by a farmers' organization. At least 450,000 hectares (1.2 million acres) were destroyed in Kebbi, the country's main rice-growing state, according to Mohammed Sahabi, the state chairman of the Rice Farmers Association of Nigeria. Planters had targeted a 2.5 million ton contribution to the national basket, but will now meet less than 20% of the target.

Farmers in five other states -- Kano, Nigeria, Enugu, Jigawa and Nasarawa -- also reported damage. "Although we heard the forecast of flooding this year, we didn't expect that the damage will be of this magnitude,"…. (Read more)

វៀតណាម ( Vietnam )

### តម្លៃអង្ករនាំចេញរបស់វៀតណាមកើនឡើងខ្ពស់បំផុត ក្នុងរយៈពេល៩ឆ្នាំ

## Vietnamese rice export price hits 9 year high

*VN Express: September 05,*



The average export price of Vietnamese rice in the first seven months jumped to $487.2 per tonne, the highest level since 2011.
This marks a year-on-year increase of 12.5 percent, according to the Agriculture Products Processing and Development Department.

The Covid-19 pandemic has pushed many countries to increase rice purchases for bolstering reserves, leading to higher prices, it said. (Read more)

វៀតណាម ( Vietnam )

### អង្ករវៀតណាមអាចនឹងនាំចេញនៅក្នុងតម្លៃ ៣០០០ ទៅ៤០០០ ដុល្លារក្នុងមួយតោន ដើម្បីសម្របទៅនឹងស្តង់ដារ

## Meeting standards, Vietnamese rice may be exported at price of US$3,000 – 4,000 per ton

*Custom News: September 05, 2020*

After the EVFTA took effect, Trung An Company signed a contract to export fragrant rice to the EU with FOB price (Free On Board) of US$1,080 per ton. While before the EVFTA, the highest export price that the company achieved was only US$800 per ton.



Mr. Binh said: "Vietnam's business culture is very poor, when a market is open, enterprises will race to reduce prices to compete and dominate (Read more)

## ជំនួបជាមួយក្រុមហ៊ុន Fuji Electric Co., Ltd. ពិភាក្សាអំពីលទ្ធភាពក្នុងកិច្ចសហការលើការច្នៃប្រឌិតបច្ចេកវិទ្យាថាមពល

## Meeting with Fuji Electric Co., Ltd. Discussing the possibilities of cooperating on Innovating Energy Technology







នាព្រឹកថ្ងៃអង្គារ ១៤កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ **សហព័ន្ធស្រូវអង្ករកម្ពុជា** ដែលមានលោក **លន់ យ៉េង** អគ្គលេខាធិការសហព័ន្ធ បានទទួលជួបស្វាគមន៍ ក្រុមហ៊ុន Fuji Electric Co., Ltd. ដែលជាក្រុមហ៊ុនរបស់ប្រទេសជប៉ុន ផ្តោតលើការច្នៃប្រឌិតបច្ចេកវិទ្យាថាមពល (Innovating Energy Technology) តំណាងដោយ **លោក ហាជិម៉ិ អ៊ីវ៉ាសាគិ** (Hajime Iwasaki) នាយកគ្រប់គ្រងការិយាល័យតំណាងនៅកម្ពុជា ដែលជំនួបនេះ ផ្តោតសំខាន់ទៅលើការណែនាំពីសក្តានុពលរបស់ក្រុមហ៊ុន និងលទ្ធភាពក្នុងការចាប់ដៃគូសហការរវាងក្រុមហ៊ុននេះ និងរោងម៉ាស៊ីនកិនស្រូវ ដែលជាសមាជិករបស់សហព័ន្ធ។

បន្ទាប់ពីខាង Fuji Electric Co., Ltd. បានរៀបរាប់ពីសាវតា និងគម្រោងនានាដែលក្រុមហ៊ុនមាននៅក្នុងប្រទេសកម្ពុជា ដែលមានដូចជា Minebea Substation, supplying MV panel, CRT, MDB, UPS, monitoring system of solar power, distribution transformer (Oil Immersed type, cast resin type), SCADA system, Crane System, VSD Panel ជាដើមនេះ សហព័ន្ធស្រូវអង្ករកម្ពុជាយល់ឃើញថា នេះជាឱកាសដ៏ល្អមួយ ក្នុងការណែនាំបន្តទៅកាន់សមាជិករបស់សហព័ន្ធ ដែលជារោងម៉ាស៊ីនកិនស្រូវ ដោយសារតែ តម្រូវការថាមពល និងម៉ាស៊ីននានាទៅតាមបច្ចេកវិទ្យា គឺជាការចាំបាច់ ជាពិសេសសម្រាប់រោងម៉ាស៊ីនកិនស្រូវខ្នាតតូចដែលកំពុងតែអភិវឌ្ឍខ្លួនទៅជាខ្នាតមធ្យម និងខ្នាតធំជាដើម។

ជាកិច្ចបញ្ចប់នៃជំនួបនេះ សហព័ន្ធស្រូវអង្ករកម្ពុជា សម្តែងក្តីស្វាគមន៍ចំពោះក្រុមហ៊ុន Fuji Electric Co., Ltd. ក្នុងករណីក្រុមហ៊ុនចាប់អារម្មណ៍ក្លាយជាសមាជិកសហព័ន្ធ ហើយជាពិសេសនោះ វានឹងក្លាយជាឱកាសដ៏ល្អមួយ ក្នុងការចាប់ដៃគូសហការ និងពិភាក្សាអំពីលក្ខណៈបច្ចេកទេសឱ្យបានកាន់តែស៊ីជម្រៅជាមួយនឹងរោងម៉ាស៊ីនកិនស្រូវ ដែលជាសមាជិករបស់សហព័ន្ធផងដែរ។

On September 01, 2020, Cambodia Rice Federation (CRF), represented by **Mr. Lun Yeng, Secretary General of CRF,** has welcomed the innovating Energy Technology Japanese Company, Fuji Electric Co., Ltd., represented by **Mr. Hajime Iwasaki, Manager of Fuji Electric Co., Ltd** in Cambodia Representative Office. This meeting focuses on the introduction of Company profile and its project references in Cambodia, and also discussing on the possibilities of cooperating between this company with CRF's member, rice mills.

Fuji Electric Co., Ltd introduced about their company profile and project references such as Minebea Substation, supplying MV panel, CRT, MDB, UPS, monitoring system of solar power, distribution transformer (Oil Immersed type, cast resin type), SCADA system, Crane System, VSD Panel. Etc. After getting to understand these potentials, CRF perceive positive thought that it will be a good chance for further introducing to CRF's members, who are rice mills, as the needed of energy and machine is very essential, especially for those who expand their rice mills from small to medium or large size.

As the result of the meeting, CRF expresses our warm welcome in case of Fuji Electric Co., Ltd. interested to be one of CRF's member. In particular, it will be a great opportunity to partner, collaborate and discuss on technical aspects in depth with the CRF's members.

## សមាជិកក្រុមប្រឹក្សាភិបាលសហព័ន្ធស្រូវអង្ករកម្ពុជា ជួបពិភាក្សាផ្សព្វផ្សាយអង្ករខ្មែរ សុវត្ថិភាព និងសុខភាពល្អ ជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI

## CRF's Board Member Meet CDRI to Promote Cambodia's Rice with Safety and Healthy




នាព្រឹកថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០ **លោក យ៉ន សុវណ្ណ សមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា** បានអញ្ជើញទស្សនកិច្ច និងជួបជាមួយ **លោកបណ្ឌិត ប៉ិច សុខេម នាយកប្រតិបត្តិវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI) ដែលជំនួបនេះផ្តោតលើការពិភាក្សាផ្លាស់ប្តូរយោបល់លើការផលិតស្រូវសែនជ័យប្រេន (Senchey Low Glycemic Index: GI) ដែលត្រូវបានលោក យ៉ន សុវណ្ណ កែលម្អ ដោយរួមសហការជាមួយ/លើកទឹកចិត្តពី មូលនិធិ GI នៅអូស្ត្រាលី និងវិទ្យាស្ថាននៅសឹង្ហបុរី។

លោកបណ្ឌិត ប៉ិច សុខេម បានសរសើរដល់លោក យ៉ន សុវណ្ណ ចំពោះចក្ខុវិស័យពិសេសរបស់លោក ក្នុងការផ្សព្វផ្សាយអង្ករខ្មែរ សុខភាពល្អ សុវត្ថិភាព និងការប្រកួតប្រជែងខ្ពស់សម្រាប់អតិថិជន។

On September 2, 2020 morning, **Mr. Yon Sovann, Board member of the Cambodia Rice Federation (CRF),** visited **the Cambodia Development Resource Institute (CDRI)** to discuss and exchange views with **Dr. PECH Sokhem, PhD, Executive Director of CDRI** on the Senchey Low Glycemic Index (GI) rice products being developed and promoted by Mr. Sovann in collaboration with/encouragement from GI foundation in Australia and institute in Singapore.

Dr. Pech Sokhem praised Mr. Yon Sovann for his vision in promoting Cambodia's rice that is healthy, safe, and highly competitive for customers.



# ការចុះអនុស្សរណៈនៃការយោគយល់គ្នារវាងសហព័ន្ធស្រូវអង្ករកម្ពុជា និងធនាគារចិន (ហុងកុង) សាខាភ្នំពេញ លើគម្រោង ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន លើកទី៣ ឆ្នាំ២០២០

## MOU between Cambodia Rice Federation and Bank of China (Hong Kong) Limited Phnom Penh Branch on the 3rd China International Import Expo (CIIE) project




នាព្រឹកថ្ងៃសុក្រ ២រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ នាទីស្នាក់ការធនាគារចិន (ហុងកុង) សាខាភ្នំពេញ **សហព័ន្ធស្រូវអង្ករកម្ពុជា** (**ស.អ.ក**) ដែលតំណាងដោយ **ឧកញ៉ា សុង សារ៉ន** ប្រធានសហព័ន្ធ បានចុះអនុស្សរណៈនៃការយោគយល់គ្នាលើគម្រោង **ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន លើកទី៣** ជាមួយនឹង **ធនាគារចិន (ហុងកុង) សាខាភ្នំពេញ** ដែលតំណាងដោយ **លោក** Liu Zheng។

ក្នុងនាមជាដៃគូយុទ្ធសាស្ត្រមួយរបស់ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិនលើកទី៣ ធនាគារចិន (ហុងកុង) យល់ឃើញនិងទទួលស្គាល់ ស.អ.ក ជាសមាគមធុរកិច្ចសំខាន់នៅកម្ពុជា ជាមួយនឹងគុណសម្បត្តិនៃការដែលសហព័ន្ធមានសមាជិកជាច្រើន ជាពិសេសគឺក្រុមហ៊ុននាំចេញ និងរោងម៉ាស៊ីនកិនស្រូវ ដែលជាឱកាស ក្នុងការពង្រីកនូវសក្ដានុពលនៃកិច្ចសហការរវាងសមាជិករបស់សហព័ន្ធ និងធនាគារចិន ក៏ដូចជាផ្សព្វផ្សាយបន្ថែមទៅដល់សមាជិក ក្នុងការចូលរួម ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន លើកទី៣ ដើម្បីទទួលបានឱកាសពង្រីកធុរកិច្ច និងពាណិជ្ជកម្មសកលផងដែរ។

យោងតាម សេចក្ដីប្រកាសរបស់ពិព័រណ៍ទំនិញនាំចូលអន្តរជាតិចិន ពិព័រណ៍លើកទី៣នេះ គ្រោងនឹងរៀបចំ នៅថ្ងៃទី០៥ ដល់ទី១០ ខែវិច្ឆិកា ឆ្នាំ២០២០ ខាងមុខ នាទីក្រុងសៀងហៃ ប្រទេសចិន។ សហព័ន្ធស្រូវអង្ករកម្ពុជា មានសុទិដ្ឋិនិយម និងសង្ឃឹមយ៉ាងមុតមាំ ក្នុងការចូលរួមយ៉ាងសកម្ម នៅក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ ដើម្បីផ្សព្វផ្សាយអំពីអង្ករកម្ពុជានៅលើឆាកអន្តរជាតិ និងពង្រីកក៏ដូចជាស្វែងរកដៃគូពាណិជ្ជកម្ម នៅក្នុងវិស័យស្រូវអង្ករ និងវិស័យពាក់ព័ន្ធនានា នៅក្នុងឱកាសនៃពិព័រណ៍នោះផងដែរ។







Click here for English Version : [MOU between CRF and Bank of China](MOU between CRF and Bank of China)

## តម្លៃស្រូវ និងតម្លៃអង្ករនាំចេញ
## (Paddy price & FOB Price)

### សហព័ន្ធស្រូវអង្ករកម្ពុជា (Cambodia Rice Federation)

**ប្រធានក្រុមប្រឹក្សាភិបាល (Chairman)**
*លោកឧកញ៉ា ហ៊ិន ឡាក់ (Oknha Hun Lak)*

**ប្រធានសហព័ន្ធ (President)**
*លោកឧកញ៉ា សុង សារ៉ន (Okhna Song Saran)*

**អគ្គលេខាធិការ (Secretary General)**
*លោក លន់ យ៉េង (Mr. Lun Yeng)*

**រៀបរៀង និងចងក្រងដោយ (Compiled by)**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*

**រចនាដោយ (Designed by)**
*កញ្ញា សន ឆវីតី - មន្ត្រីសម្របសម្រួលទំនាក់ទំនង*
*(Ms. Sorn Chhorvyvatey - Communication Coordinator)*



សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃអង្ករនាំចេញ FOB Price
as of 31 August 2020

| Rice Varieties | Rice Standard (Price USD/ MT) 5% | 10% | 15% |
|---|---|---|---|
| Jasmine Rice (Malys Angkor) | 900 | | |
| Standard Fragrant Rice_SKO | 785 | | |
| White Rice_Premium (Soft cooking) | 600 | | |
| Parboiled Rice | 570 | | |
| Organic Parboiled Rice (Premium Quality) | 1000 | | |
| Organic White Rice (Premium Quality) | | | 950 |
| Organic Jasmine (Malys Angkor) | 1400 | | |
| Organic Brown Jasmine (Premium Quality) | | 1370 | |

**Source :** Cambodian Exporters and Millers
**Note:** Price Fluctuation : +/- 2%



សហព័ន្ធស្រូវអង្ករកម្ពុជា
Cambodia Rice Federation

តម្លៃស្រូវសើម នៅតាមទីតាំង ដែលកំពុងប្រមូលផល តាមបណ្ដាខេត្តមួយចំនួន
ថ្ងៃសុក្រ ទី០៤ ខែកញ្ញា ឆ្នាំ២០២០

| ខេត្ត | ស្រុក | ស្រូវសែនក្រអូប | ស្រូវអ៊ីអែរ | ស្រូវផ្សេងៗ |
|---|---|---|---|---|
| កំពង់ចាម | ជើងព្រៃ[1] | ១២០០ | ៩១០ | |
| | បាធាយ | | ៩៥០ | |
| កំពង់ធំ | ស្ទឹងសែន[2] | | *៩៤០ | |
| | កំពង់ស្វាយ[3] | | *៩៤០ | |
| | ស្ទោង[4] | | *៨៨០ | |
| | សន្ទុក[5] | | *៩២០ | |
| សៀមរាប | ពួក[6] | ១០៥០ | *៨៨០ | |
| ព្រះវិហារ | ឆែប | | *៩២០ | |
| បន្ទាយមានជ័យ | ភ្នំស្រុក | ១២០០ | *៩០០ | |
| | ព្រះនេត្រព្រះ | ១១៥០ | *៨៩០ | |
| | មង្គលបុរី | | ** ៩១០ | |
| បាត់ដំបង | ឯកភ្នំ[7] | | | ៩១០ |
| | បវេល[8] | ១២២០ | | |
| | បាណន់ | ១២០០ | | |
| ពោធិសាត់ | បាកាន | ១២០០ | ៨៥០ | |
| កំពង់ឆ្នាំង | រលាប្អៀរ[9] | | ៩០០ | ១០៧០ |

គិតជារៀល/គីឡូក្រាម

**កំណត់សម្គាល់៖**
*ពូជស្រូវអុីមែ ៥៤៥១ ** ពូជស្រូវអុីមែ ៨៥
1. សហគមន៍កសិកម្មទួលព្រះវិហារ ស្រុកជើងព្រៃ ខេត្តកំពង់ចាម (089 412 149) នឹងបន្តប្រមូលផលស្រូវសែនក្រអូប ដែលនៅសល់ប្រមាណ៣០ហិកតា រីឯស្រូវអុីអែរ សល់បន្តិចបន្តួច។
2. សហគមន៍កសិកម្មអូរកន្ធមានជ័យ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ (012 214 628) នឹងបន្តប្រមូលផលស្រូវអុីមែ៥៤៥១ដែលនៅសល់ប្រមាណ ១៥០ហិកតា។ 3. សហគមន៍កសិកម្មឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (078 576 321) នឹងបន្តប្រមូលផលស្រូវអុីមែដែលនៅសល់ប្រមាណ ១០០ហិកតា។ 4. សហគមន៍ស្ទោងពន្លឺពេជ្រ ស្រុកស្ទោង ខេត្តកំពង់ធំ (012 235 944) នឹងបន្តប្រមូលផលស្រូវអុីមែដែលនៅសល់ប្រមាណ ១០០ហិកតា។ 5. សហគមន៍សន្ទុកក្រៅថ្មីថ្លើង នៅស្រុកសន្ទុក ខេត្តកំពង់ធំ (092 329 547) នឹងបន្តប្រមូលផលស្រូវអុីមែ៥៤៥១ ដែលនៅសល់ប្រមាណ៣០ហិកតា។ 6. សហគមន៍សំរោងយាមានជ័យ ស្រុកពួក ខេត្តសៀមរាប (097 561 1118) នឹងបន្តប្រមូលផលស្រូវសែនក្រអូបដែលនៅសល់ប្រមាណ ៤០ ហិកតា និងស្រូវអុីមែនៅសល់តិចតួច។ 7. សហគមន៍និរន្តរភាពចម្រើនផល ស្រុកឯកភ្នំ ខេត្តបាត់ដំបង (092 409 384) នឹងបន្តប្រមូលផលស្រូវផ្កាស្រាលប្រមាណ៨០០ហិកតា។
8. សហគមន៍សង្ហាផល ស្រុកបវេល ខេត្តបាត់ដំបង (012 675 589) បានប្រមូលផលស្រូវសែនក្រអូបបាន៦០% នៃផ្ទៃដី៣៣០ ហិកតា។
9. សហគមន៍ជ័យជម្នះ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង (092 651 689) នឹងបន្តប្រមូលផលស្រូវផ្ការំដួល ២០០ហិកតា។


(855) 23 559 8999
info@crf.org.kh
Soma Tower, 7th Floor
#2C, Street 120, Sangkat Phsar Thmey II, Khan Daun Penh, Phnom Penh, Cambodia


https://www.facebook.com/cambodiaricefederation/
www.crf.org.kh
https://twitter.com/RiceCrf
សហព័ន្ធស្រូវអង្ករកម្ពុជា Cambodia Rice Federation